ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ១៩ ខែធ្នូ ២០១៣ ដោយ អគ្គនាយកដ្ឋានពន្ធដារ

## ឯកឧត្តម គង់ វិបុល ចូលរួមជាគណៈអធិបតី ក្នុងពិធីហត្ថលេខា និងសម្ពោធជាផ្លូវការរបស់ ក្រុមហ៊ុន HML-XAT CONSULTING CO.,LTD.

នាម៉ោង ៦ល្ងាច ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៣ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមបានចូលរួមជាគណៈអធិបតីក្នុងពិធីហត្ថលេខា និងសម្ពោធជាផ្លូវការរបស់ក្រុមហ៊ុន HML-XAT CONSULTING CO.,LTD នៅសណ្ឋាគារ Inter-Continental រាជធានីភ្នំពេញ ។

នៅក្នុងឱកាសពិធីហត្ថលេខា និងសម្ពោធជាផ្លូវការនេះ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលបានសម្ដែងនូវកិច្ចស្វាគមន៍ ព្រមទាំងបានថ្លែងនូវអំណរគុណចំពោះឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់។ ឯកឧត្តម **គង់ វិបុល** ក៏បានបញ្ជាក់ថាក្រុមហ៊ុនឯកជនជាដៃគូរដ៏សំខាន់ក្នុងការផ្ដល់សេវា និងប្រឹក្សាផ្នែកពន្ធដារដល់អ្នកជាប់ពន្ធ។ ឯកឧត្តមបានបន្តថានៅពេលដែលអ្នកជាប់ពន្ធយល់ដឹងពីច្បាប់សារពើពន្ធកាន់តែច្រើននោះ ការបង់ពន្ធក៏កាន់តែច្រើន។



ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



ឯកឧត្តម **គង់ វិបុល** និងភ្ញៀវកិត្តិយសចូលរួមពិធីសម្ពោធ

ទន្ទឹមនេះ អគ្គនាយកដ្ឋានពន្ធដារ កំពុងតែធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅដូចជាកំណែទម្រង់គោលនយោបាយសារពើពន្ធ និងកំណែទម្រង់រដ្ឋបាលសារពើពន្ធ ក្នុងគោលដៅធ្វើយ៉ាងណាពង្រឹងនូវអភិបាលកិច្ចល្អ និងតម្លាភាព គណនេយ្យភាពដល់អ្នកជាប់ពន្ធក្នុងការបង់ពន្ធជូនរដ្ឋ។

ឯកឧត្តម គង់ វិបុល ចង់ប្រែក្លាយ អគ្គនាយកដ្ឋានពន្ធដារ ទៅជាស្ថាប័នជាតិមួយនេះ ដែលជាស្ថាប័នមួយដែលនឹងទទួលបាននូវទំនុកចិត្តខ្ពស់ពីគ្រប់មជ្ឈដ្ឋានសាធារណៈ តាមរយៈការបង្កើនសមត្ថភាពមន្ត្រីពន្ធដារ ការបង្កើនការផ្ដល់សេវាល្អជូនអ្នកជាប់ពន្ធជាដើម។



